**Declassified to Public**
**06 September 2012**

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**Royaume du Cambodge**

**Nation Religion Roi**

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 05 / 05 / 2008
ម៉ោង (Time/Heure): 9:35
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**

**Office of the Co-Investigating Judges**

**Bureau des Co-juges d'instruction**

**សំណុំរឿងព្រហ្មទណ្ឌ**

**Criminal Case File /Dossier pénal**

**លេខ/No: 002/14-08-2006**

**លេខស៊ើបសួរ/Investigation/Instruction**

**លេខ/No: 001/18-07-2007-ECCC-OCIJ**

## កំណត់ហេតុនៃការសួរចម្លើយ

## Written Record of Interview of Charged Person

## Procès-verbal d'interrogatoire

ឯកសារបានចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certifified Date/Date de certification): 05 / 05 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

ឆ្នាំពីរពាន់ប្រាំបី ខែមេសា ថ្ងៃទីម្ភៃប្រាំបួន នៅវេលាម៉ោងដប់និងដប់ប្រាំនាទី
យើង **យូ ប៊ុនឡេង** និង Marcel Lemonde ជាសហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញ
ដោយមានលោក ហម ហ៊ែល និង លោក លី ច័ន្ទតុលា ជាក្រឡាបញ្ជីអមផង
បានឃើញច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤
បានឃើញវិធាន ៥៨ នៃវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញ
ដោយមានវត្តមានរបស់ អ៊ុច ចាន់ណូរ៉ា និង តាន់ប៊ាង ដាវ័ណ្ណ ជាអ្នកបកប្រែនៃអង្គជំនុំជម្រះវិសាមញ្ញដែលបានស្បថរួចហើយ។

ជនត្រូវចោទដែលមានអត្តសញ្ញាណដូចខាងក្រោម បានចូលខ្លួននៅចំពោះមុខយើង:
ឈ្មោះ**កាំង ហ្គេកអ៊ាវ** ហៅ **ឌុច** ភេទ ប្រុស កើតថ្ងៃទី ១៧ ខែវិច្ឆិកា ឆ្នាំ ១៩៤២។
ត្រូវដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យពី **បទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ** និង **ការរំលោភបំពានធ្ងន់ធ្ងរនៃអនុសញ្ញាទីក្រុងហ្សឺណែវចុះថ្ងៃទី ១២ ខែសីហា ឆ្នាំ ១៩៤៩**

បទល្មើសដែលមានចែង និង ផ្តន្ទាទោស តាមមាត្រា ៥ មាត្រា ៦ មាត្រា ២៩ (ថ្មី) និង មាត្រា៣៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤។

ច្បាប់ដើមនៃកំណត់ហេតុនេះ ត្រូវបានសរសេរជាភាសាខ្មែរ។

សហព្រះរាជអាជ្ញានៃអង្គជំនុំជម្រះវិសាមញ្ញ លោក Robert Petit និង អ្នកស្រី ជា លាង ដែលត្រូវបានជូនដំណឹងត្រឹមត្រូវរួចហើយអំពីការសួរចម្លើយនេះ នៅក្នុងលិខិតជូនដំណឹង ចុះថ្ងៃទី ០៩ ខែមេសា ឆ្នាំ២០០៨ ៖

☒ អ្នកស្រី ជា លាង ត្រូវបានតំណាងដោយលោក យ៉េត ចរិយា សហព្រះរាជអាជ្ញារង។

☒ លោក Robert Petit ត្រូវបានតំណាងដោយលោក Alex Bates ជំនួយការជាន់ខ្ពស់របស់សហព្រះរាជអាជ្ញា។

លោកមេធាវី **ការ សាវុត្ថ** និង Francois Roux សហមេធាវីរបស់ជនត្រូវចោទត្រូវបានកោះអញ្ជើញ នៅក្នុងដីកាកោះអញ្ជើញចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០០៨ និង មានលទ្ធភាពបានពិនិត្យសំណុំរឿងតាំងពីពេលនោះមក មានវត្តមានទាំងពីរនាក់។

**ការសួរចម្លើយ**

**សួរ-ឆ្លើយ:**

**សំនួររបស់លោកសហចៅក្រមស៊ើបអង្កេត:** លោក បានប្រកាសប្រាប់យើងអំពីសេចក្តីសង្កេតជាលាយលក្ខណ៍អក្សររបស់លោក លើបទសម្ភាសន៍របស់លោកនៅឆ្នាំ១៩៩៩ និង លើសៀវភៅរបស់លោក ដេវីដ ឆេនល័រ (David Chandler) ដែលមានចំណងជើងថា *"សម្លេងពីមន្ទីរស-២១"* ។ រហូតមកដល់ពេលនេះ យើង មិនទាន់បានទទួលការកត់សម្គាល់ទាំងនោះនៅឡើយទេ...

**ឆ្លើយ:** ទាក់ទងនឹងសៀវភៅរបស់លោកឆេនល័រ មានចំនុចសំខាន់ៗជាច្រើន ជាពិសេស ចំនុចទាក់ទងនឹងសេចក្តីសម្រេចថ្ងៃទី៣០ ខែមិនា ឆ្នាំ១៩៧៦ ទាក់ទងនឹងបទឧក្រិដ្ឋដែលត្រូវបានបញ្ជូនទៅស២១។ មានចំនុចមួយទៀតផងដែរ (ទំព័រ ១៥៤-១៥៥ ជាភាសាបារាំង) ដែលទាក់ទងនឹងការទាក់ទងគ្នារវាងប៉ុលពតជាមួយនឹង កាង សិន (ជាមនុស្សជំនិតរបស់ម៉ៅសេទុង)។ ខ្ញុំ សុំលើកឡើងផងដែរអំពីទំនាក់ទំនងរវាងប៉ុលពតជាមួយនឹង Zhang Chunqiao (ជាបុគ្គលទី២នៃក្រុម៤នាក់)។ ខ្ញុំ មិនទាន់បានបញ្ចប់កិច្ចការដ៏សំខាន់នេះនៅឡើយទេ ហើយ ខ្ញុំ នឹងប្រគល់ជូនលោកចៅក្រមនូវការកត់សម្គាល់ជាលាយលក្ខណ៍អក្សររបស់ខ្ញុំ នៅថ្ងៃច័ន្ទក្រោយយ៉ាងយូរ។ ហើយ ដូចគ្នាដែរ ចំពោះការកត់សម្គាល់របស់ខ្ញុំ លើកិច្ចសម្ភាសន៍ជាមួយ Christophe Peschoux។

**សំនួររបស់លោកសហចៅក្រមស៊ើបអង្កេត:** លោក បានពន្យល់កាលពីមុនថាលោកជាអ្នកទទួលខុសត្រូវលើមន្ទីរម១៣ មុនការរំដោះ។ តើលោកអាចប្រាប់យើងឲ្យច្បាស់លាស់ថាតើនាកាលបរិច្ឆេទណាដែលលោកកាន់កាប់តួនាទីនេះ? ផងដែរ មានសាក្សីមួយចំនួនបានប្រកាសថានាសម័យនោះ លោក ខ្លួនឯងផ្ទាល់បានធ្វើទារុណកម្ម និង បានសម្លាប់មនុស្ស។ តើលោក មានយោបល់ដូចម្តេចពីរឿងនេះ?

**កំណត់សម្គាល់របស់លោកមេធាវី** Francois Roux: តាងនាមឲ្យមេធាវីការពារក្តី ខ្ញុំ សុំឲ្យកូនក្តីខ្ញុំកុំឆ្លើយនឹងសំនួរទាក់ទិននឹងម១៣នេះ (លើកលែងតែចំនុចទាក់ទិននឹងកាលបរិច្ឆេទ)។ អង្គហេតុទាំងនេះ មិនស្ថិតនៅក្រោមសមត្ថកិច្ចរបស់តុលាការនេះទេ។

**សំនួររបស់លោកសហចៅក្រមស៊ើបអង្កេត:** អង្គហេតុទាំងនេះ ពិតជាមិនស្ថិតនៅក្នុងសមត្ថកិច្ចរបស់តុលាការមែនហើយ លោក ក៏មិនអាចត្រូវបានកាត់ទោសលើអង្គហេតុទាំងនេះដែរ ប៉ុន្តែ វាជាការសំខាន់ដែលត្រូវប្រាប់លោកថាសាក្សី បាននិយាយថាលោកខ្លួនឯងបានធ្វើទារុណកម្មនិងសម្លាប់អ្នកទោស ដើម្បីផ្តល់លទ្ធភាពឲ្យលោកអាចឆ្លើយតបនឹងការលើកឡើងទាំងនេះ។

**ឆ្លើយ:** ខ្ញុំ ជាប្រធានម១៣ ពីថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៧១ ដល់ ថ្ងៃទី១ ខែមករា ឆ្នាំ១៩៧៥។ ចំពោះចំនុចផ្សេងទៀត ខ្ញុំ សុំមិននិយាយ។

**សំនួររបស់លោកសហព្រះរាជអាជ្ញា:** លោកនិយាយអំពីថ្ងៃទី១ ខែមករា ឆ្នាំ១៩៧៥ ហើយ លោក បានបញ្ជាក់ថាលោកបានចាប់ផ្តើមធ្វើការនៅស២១ ចាប់ពីថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧៥។ វា ហាក់ដូចជាថាសកម្មភាពរបស់លោកនៅម១៣ ត្រូវបានបន្តលើសពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ទៅទៀត ហើយ តាមរយៈនេះ ស្ថិតនៅក្នុងសមត្ថកិច្ចរបស់អង្គជំនុំជម្រះ។

**ឆ្លើយ:** តាមពិតទៅ ម១៣ លែងមានទៀតហើយចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ១៩៧៥០: លែងមានការសួរចម្លើយ ការសម្លាប់ និង ការបញ្ជូនអ្នកទោសថ្មីមកទៀតហើយ។ យើង បានរក្សាទុកអ្នកទោសរហូតដល់ថ្ងៃទី៣០ ខែមេសា ជាកាលបរិច្ឆេទដែលសុនសេន បានបញ្ជាឲ្យដោះលែងអ្នកទោសនៅម១៣-ខ ហើយ ឲ្យបញ្ជូនអ្នកទោសពីម១៣-ក ទៅតំបន់៣២ ហើយ បានឲ្យគេសម្លាប់អ្នកទោសមួយចំនួន។ ចាប់តាំងពីពេលនោះមក និង រហូតដល់ថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៧៥ ខ្ញុំ មិនមានតួនាទីអ្វីទេ ហើយ ខ្ញុំ បានជិះម៉ូតូដើរលេង។ ខ្ញុំ សុំបញ្ជាក់ថានាពេលនោះ ខ្ញុំរង់ចាំចម្លើយទាក់ទងនឹងពាក្យសុំប្តូរទៅធ្វើការងារនៅក្រសួងឧស្សាហកម្មរបស់ខ្ញុំ។ ប៉ុន្តែ ចុងក្រោយ គឺជាចម្លើយអវិជ្ជមាន។ ម៉្យាងទៀត ខ្ញុំ បានសុំការអនុញ្ញាតរៀបការជាមួយប្រពន្ធខ្ញុំពីអង្គការ។ អង្គការ បានយល់ព្រម ប៉ុន្តែ មិនបានកំណត់កាលបរិច្ឆេទនៃអាពាហ៍ពិពាហ៍ទេ។ ប្រពន្ធខ្ញុំ បានព្យាយាមពន្យាពេល ដោយសារតែ ដោយឃើញថាខ្ញុំមិនមានការងារធ្វើ គាត់ខ្លាចថាខ្ញុំត្រូវបានចាប់ខ្លួនដោយសារខ្ញុំជាបញ្ញាជន និង ខ្លាចក្លាយខ្លួនជាមេម៉ាយ ឬ ត្រូវបានគេចាប់ខ្លួន (ទីបញ្ចប់ ពួកយើង បានរៀបការនៅថ្ងៃ២០ ខែធ្នូ ឆ្នាំ១៩៧៥)។

នៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៧៥ ខ្ញុំ បានចូលរួមក្នុងវគ្គរៀនសូត្រមួយ ហើយ បានចូលកាន់តំណែងរបស់ខ្ញុំនៅស២១ នៅថ្ងៃទី ១៥ ខែសីហា ឆ្នាំ១៩៧៥។ និយាយឱ្យច្បាស់ទៅ ដូចដែលខ្ញុំបានពន្យល់កាលពីថ្ងៃទី៧ ខែសីហា កន្លងទៅ សុនសេន បានកោះហៅខ្ញុំជាមួយណាតដើម្បីប្រកាសប្រាប់យើងពីការបង្កើតស២១។ បន្ទាប់មក ខ្ញុំ បាននាំកម្លាំងរបស់ខ្ញុំពីអមលាំង។ នៅខែកញ្ញា ខ្ញុំ បានទទួលបញ្ជាឱ្យទៅប្រមូលរឹបអូសគ្រប់ឯកសារសំខាន់ៗពីរដ្ឋការរបស់លន់នុល ជាពិសេសពីអគ្គនាយកដ្ឋាននគរបាលជាតិ និង បញ្ជាការដ្ឋានកងទ័ព។ ហើយ គឺនៅខែតុលា ឆ្នាំ១៩៧៥ ដែលស២១ ចាប់ដំណើរការពិតប្រាកដ។

**សំនួររបស់លោកសហចៅក្រមស៊ើបអង្កេត:** ត្រឡប់មករកតួនាទីផ្ទាល់ខ្លួនរបស់លោក ទាក់ទងនឹងការធ្វើទារុណកម្មនិងការសម្លាប់វិញ។ តើលោកនៅតែនិយាយថានៅស២១ លោក ខ្លួនឯងផ្ទាល់ មិនដែលបានធ្វើទារុណកម្ម (លើកលែងតែករណីដែលលោកបានចូលរួមតិចតួច) ហើយ មិនដែលបានសម្លាប់នរណាម្នាក់ផ្ទាល់ដៃនោះទេទៀតឬ?

**ឆ្លើយ:** ខ្ញុំ នៅតែរក្សាការប្រកាសរបស់ខ្ញុំដដែល។

**សំនួររបស់លោកសហព្រះរាជអាជ្ញា:** នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៧៥ តើមាននៅសល់អ្នកទោសប៉ុន្មាននៅម១៣? តើ មានអ្នកទោសប៉ុន្មានដែលត្រូវបានសម្លាប់? យ៉ាងដូចម្តេច? តើលោកខ្លួនឯងផ្ទាល់មានបានរៀបចំការបញ្ជូនទៅសម្លាប់ដែរឬទេ? តើលោកមានបានចូលរួមសម្លាប់ដែរឬទេ?

**ឆ្លើយ:** មានអ្នកទោសនៅសល់តិចតួច: ប្រហែលជាពី៥ទៅ១០នាក់នៅម១៣-ក និង ប្រហែលជាជាង១០០នាក់នៅម១៣-ខ។ ចំពោះចំនួនពិតប្រាកដនៃអ្នកទោសដែលត្រូវបានសម្លាប់ ឬ បញ្ជូនទៅតំបន់៣២ ខ្ញុំ បានភ្លេចអស់ហើយ។ ខ្ញុំ នៅចាំបានតែថាខ្ញុំបានសុំឱ្យដោះលែង ហាមអ៊ីន ហើយ សុនសេន បានបដិសេធ ហើយ បានបញ្ជាថាជននេះត្រូវតែបញ្ជូនទៅតំបន់៣២។ ខ្ញុំ មិនបានចូលរួមសម្លាប់ដោយផ្ទាល់នោះទេ។ ខ្ញុំ បានផ្ទេរការងារនេះទៅឱ្យប្រាក់មាស។ ខ្ញុំ សុំបញ្ជាក់ថា រៀងរាល់ថ្ងៃខ្ញុំបានឃើញលក្ខខណ្ឌនៃការឃុំខ្លួននៅម១៣ ហើយ ដោយសារមូលហេតុនេះហើយបានជា នៅស២១ ខ្ញុំបានព្យាយាមគេចមិនមើលលក្ខខណ្ឌនៃការឃុំខ្លួននៅស២១នេះ។ ប្រាក់មាសជាអ្នកទទួលខុសត្រូវផ្នែកឃុំឃាំងនិងសម្លាប់នៅម១៣-ក។ ប៉ុន ជាអ្នកទទួលខុសត្រូវផ្នែកសួរចម្លើយនៅទីនោះដែរ។ ចំណែកនៅម១៣-ខ វិញ ហូគឹមអេង ហៅ ស៊ុំ ជាប្រធាន។ ចំពោះខ្ញុំវិញ ខ្ញុំ ជាអ្នកពិនិត្យការងារទាំងអស់។

**កំណត់សម្គាល់របស់លោកមេធាវី** Francois Roux: មេធាវីការពារក្តី សុំឱ្យកត់សម្គាល់ថា សំនួររបស់សហព្រះរាជអាជ្ញាទាក់ទងនឹងដំណើរការរបស់ម១៣ និង អង្គហេតុដែលទាក់ទងនេះ មិនមានបានបញ្ជាក់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនោះទេ។ នេះ ជាអ្វីដែលអាចនាំឱ្យមានមោឃភាពបាន។ ដូច្នេះ សុំឱ្យសហព្រះរាជអាជ្ញាគោរពអ្វីដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។

**កំណត់សម្គាល់របស់លោកសហព្រះរាជអាជ្ញា:** អង្គហេតុនេះ អាចមានប្រយោជន៍ទាក់ទងនឹងបុគ្គលិកលក្ខណៈរបស់ជនត្រូវចោទ ដូចដែលមានបញ្ជាក់នៅក្នុងកថាខណ្ឌ១០៤ និង ១០៥ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia, National Road 4, Choam Chao, Dangkoa Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkoa, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.

**សំនួររបស់លោកសហចៅក្រមស៊ើបអង្កេត:** យើង បង្ហាញលោកនូវឯកសារ ERN 00171139-00171144។ តើលោកអាចនិយាយប្រាប់យើងបានទេថាតើចំណារទាំងនោះ ជាចំណារដៃរបស់លោកមែនទេ?

**ឆ្លើយ:** ចំណារទាំងនេះ ជាចំណាររបស់មនុស្សច្រើនគ្នា។ នៅទំព័រទី១ (ERN 00171139) ខ្ញុំទទួលស្គាល់ថាជាចំណាររបស់ខ្ញុំ ដែលចារថា "*វាយចោល*" និង "*កូនអាហ៊ុង=ទុកសួរ*"។ ចំពោះបន្ទាត់ដែលគូសចោល ខ្ញុំ មិនដឹងថាតើនរណាជាអ្នកបានគូសបន្ទាត់នោះនោះទេ។ នៅទំព័រដដែលនេះ ខ្ញុំទទួលស្គាល់ចំណាររបស់ខ្ញុំដែរ នៅត្រង់លេខ១ និង លេខ២ ដែលមានគូសរង្វង់ជុំវិញ ("①" និង "②") នៅចុងបន្ទាត់លេខ ៤៤ និង ៤៥។ ផ្ទុយទៅវិញ ចំពោះកាលបរិច្ឆេទ២ (*២៨-០៣-៧៨ និង ១៥-០៣-៧៨*) ខ្ញុំគិតថាមិនមែនខ្ញុំជាអ្នកសរសេរវាទេ។

លើទំព័រ ERN 00171141 មិនមែនខ្ញុំជាអ្នកសរសេរ "*ទុកសិន*" នៅលើបន្ទាត់៣៥ និង ៤១ ទេ។ គឺ ប្រហែលជាប៉េង ជាអ្នកសរសេរ។

លើទំព័រ ERN 00171142 ខ្ញុំទទួលស្គាល់អក្សររបស់ខ្ញុំដែលចារថា "*ទុកសួរវិញ*", "*ពិសោធន៍ថ្នាំ*" និង "*សួររកពួករាជការចាស់នៅម្ដុំវា*"។

លើទំព័រ ERN 00171143 ខ្ញុំទទួលស្គាល់ថាជាអក្សរខ្ញុំ ដែលចារថា "*កុំយកចេញ*" និង "*កុំយកចេញក្រៅ*"។

លើទំព័រ ERN 00171144 ខ្ញុំទទួលស្គាល់ថាជាអក្សរខ្ញុំ ដែលចារថា "*ទុកសួរ= កុំយកចេញ*" និង "*កុំយកចេញ*"។

**សំនួររបស់លោកសហចៅក្រមស៊ើបអង្កេត:** តើលោកអាចបញ្ជាក់ថាតើពាក្យ "*ពិសោធន៍ថ្នាំ*" នៅទំព័រ 00171142 មានន័យដូចម្ដេច?

**ឆ្លើយ:** វា មិនមែនជាអ្វីដែលដូចអ្វីដែលខ្ញុំបាននិយាយកាលពីមុនមកនោះទេ។ ខ្ញុំ បានពន្យល់លោកចៅក្រមកាលពីលើកមុនថាការស្រាវជ្រាវថ្នាំពុល ត្រូវបានធ្វើតាមបញ្ជារបស់គណៈកម្មាធិការអចិន្ត្រៃយ៍ និយាយឲ្យចំគឺ នួនជា (ខ្ញុំ បានជំនួសសារធាតុដែលមាននៅក្នុងគ្រាប់ថ្នាំ (Capsule) ដោយម្សៅ Paracetamol)។ ខ្ញុំ បានបង្រៀនដោយខ្លួនឯងថាក្នុងការងាររបស់សន្តិបាលគឺមានការស្វែងរកថ្នាំពុលផងដែរ។ ហើយ ខ្លឹមសារនេះ មានកត់ត្រានៅក្នុងសៀវភៅកំណត់ដៃរបស់ម៉មណៃ។

ប៉ុន្តែ នៅកន្លែងនេះ គឺខុសគ្នា។ វាគឺជាប្រភេទថ្នាំថ្មីបង្កើតដោយអង្គភាព: ចាប់ពីឆ្នាំ១៩៧១មក គេបានចាប់ផ្ដើមផលិតថ្នាំពេទ្យ តាមរូបមន្តបូរាណ ស្របតាមក្បួនពេទ្យបូរាណ។ ហើយ ដោយសារមូលហេតុនេះហើយ ដែលប្លោកសេរ៉ូម ត្រូវបានជំនួសដោយទឹកដូង។ ដូចគ្នាដែរ នៅខែមេសា ឬ ឧសភា ១៩៧៧ គេបានផលិតថ្នាំ Pénicilline ដោយប្រើ "*ត្រឡោកដូង*"។ ប៉ុលពត បានបញ្ជាឲ្យអង្គភាពផ្សេងៗផលិតថ្នាំនេះ ដោយយកគំរូតាមអង្គភាពនៅសៀមរាបដែលបានផលិតវាឡើង។ ការធ្វើរបៀបនេះ ត្រូវបានបន្ត រហូតដល់ពេលមួយដែលប្រទេសចិន



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១
ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia, National Road 4, Choam Chao, Dangkoa Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkoa, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.

បានអន្តរាគមន៍ឲ្យបញ្ឈប់។ ចំពោះខ្ញុំវិញ ខ្ញុំទទួលស្គាល់ថាខ្ញុំ បានផ្តល់ការអនុញ្ញាតឲ្យមានការធ្វើពិសោធន៍បែបនេះ ដែលនាសម័យនោះខ្ញុំគិតថាជារឿងធម្មតា ប៉ុន្តែ ដែលនាពេលនេះ ខ្ញុំ ទទួលស្គាល់ថា ជាអំពើឧក្រិដ្ឋ។

**ផ្អាកការធ្វើកំណត់ហេតុនៃការសួរចម្លើយ នៅវេលាម៉ោងដប់ពីរនិងសែសិបនាទីគត់ ។**

**នៅវេលាម៉ោងដប់បួននិងសែសិបនាទីល្ងាចនៃថ្ងៃដដែល យើងចាប់ផ្តើមបន្តការសួរចម្លើយតទៅទៀត។**

**សំនួររបស់លោកសហចៅក្រមស៊ើបអង្កេត:** លោក បានពន្យល់កាលពីមុនថាលោក ជាមនុស្សតែមួយនាក់គត់ដែលអាចរាយការណ៍ទៅថ្នាក់លើ ហើយ ផ្តល់ភ្លើងខៀវចំពោះការសម្លាប់។ ហេតុដូចម្តេចបានជានៅក្នុងស្ថានភាពនេះ មនុស្សផ្សេងទៀតក្រៅពីលោក អាចធ្វើចំណារលើបញ្ជីឈ្មោះដែលយើងបានបង្ហាញលោកកាលពីព្រឹកមិញ?

**ឆ្លើយ:** ត្រូវរំលឹកថា គោលការណ៍ទូទៅនៅគ្រប់មន្ទីរសន្តិសុខទាំងអស់ ក៏ដូចជា នៅស២១ គឺ គ្រប់មនុស្សដែលត្រូវបានចាប់ខ្លួន ត្រូវតែសម្លាប់ លើកលែងតែករណីពិសេស ដែលមានភាពបណ្តោះអាសន្ន ដូចដែលខ្ញុំបានពន្យល់កាលពីមុនរួចហើយ។ សេចក្តីសម្រេចតែមួយគត់ដែលត្រូវធ្វើ គឺទាក់ទងតែនឹងពេលវេលានៃការសម្លាប់ប៉ុណ្ណោះ។ អ្នកទទួលខុសត្រូវខាងសម្លាប់គឺ ហ៊ី (ដែលមានតួនាទីដូចគ្នានេះដែរ តាំងតែពីនៅកងពល ៧០៣)។ ដូចដែលខ្ញុំ បានពិព៌ណនារួចហើយ ជាអាទិ៍ក្នុងការសួរចម្លើយចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ ២០០៧ ថាមានការផ្លាស់ប្តូរនីតិវិធី ពីព្រោះ ស៊ឺនសានី ហៅ ប្រេវ ត្រូវបានបញ្ជូនទៅសម្លាប់ សូម្បីតែការសួរចម្លើយមិនទាន់បានបញ្ចប់ក៏ដោយ: ចាប់តាំងពីពេលនោះមក មុននឹងការសម្លាប់នីមួយៗ ខ្ញុំ ត្រូវបញ្ជាក់ថាការសួរចម្លើយត្រូវបានបញ្ចប់ហើយ។ ហ៊ី បានបង្ហាញខ្ញុំនូវបញ្ជីឈ្មោះនៃមនុស្សដែលត្រូវសម្លាប់ ហើយ ខ្ញុំ គ្រាន់តែបញ្ជាក់ថាការសួរចម្លើយត្រូវបានបញ្ចប់ហើយដោយចុះហត្ថលេខា ហើយ ហ៊ី ជាអ្នកដាក់ឲ្យអនុវត្តសេចក្តីសម្រេចសម្លាប់នោះ។ ករណីតែ២លើកគត់ដែលខ្ញុំបានលូកដៃនៅក្នុងដំណើរការនៃការសម្លាប់ គឺដោយសារតែហ៊ី អវត្តមាន ដូចដែលខ្ញុំបានពន្យល់នៅក្នុងការសួរចម្លើយចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ ២០០៧ និង ថ្ងៃទី២៤ ខែមករា ឆ្នាំ២០០៨។ ខ្ញុំ សុំបញ្ជាក់ថា អវត្តមានលើកទី២របស់ហ៊ី មានរយៈពេលយូរ និង ចេះតែបន្ត ហើយ ហេតុដូច្នេះហើយទើបមានបញ្ជីឈ្មោះអ្នកទោសច្រើនដែលត្រូវសម្លាប់។ បញ្ជីឈ្មោះដែលលោកចៅក្រមបានបង្ហាញខ្ញុំកាលពីព្រឹកមិញនេះ គឺជាបញ្ជីមួយក្នុងចំណោមបញ្ជីដែលបានធ្វើឡើងនៅក្នុងពេលនៃអវត្តមានទី២របស់ហ៊ីនេះឯង។

**សំនួររបស់លោកសហចៅក្រមស៊ើបអង្កេត:** លោក បានប្រកាសថាលោកបានសួរចម្លើយអ្នកទោសតែមួយរូបគត់គឺ កុយធួន។ តើលោកអាចពន្យល់ដូចម្តេចលើឯកសារ ERN 00172738 ទាក់ទងនឹងការសួរចម្លើយឈ្មោះ លីផែល ដែលមាននិទ្ទេសថា "*អ្នកសួរចម្លើយទី១ ឌុច អ្នកសួរចម្លើយទី២ ប៉ុន*" ?

**ឆ្លើយៈ** ខ្ញុំ ត្រូវនិយាយថា ខ្ញុំ មិនមានការពន្យល់ទេទាក់ទងនឹងការណ៍នេះ ។ គឺខ្ញុំ ជាអ្នកសរសេរឈ្មោះរបស់ខ្ញុំ ហើយ ប្រហែលជាតាមការបញ្ជារបស់សុនសេន ប៉ុន្តែ ដោយមូលហេតុណាមួយនោះដែលខ្ញុំមិនដឹង។ ខ្ញុំ មិនចាំសូម្បីតែមុខរបស់លីផែល។ ប៉ុន្តែ ខ្ញុំ នៅចាំច្បាស់ថា ខ្ញុំ បានសួរចម្លើយមនុស្សតែមួយនាក់ទេគឺ កុយធួន។ វា អាចផងដែរថា សុនសេន ជាអ្នកចង់ ដោយបញ្ជាឲ្យខ្ញុំដាក់បញ្ចូលឈ្មោះរបស់ខ្ញុំ ដើម្បីបង្ហាញទៅភូមិភាគបូព៌ាថាការសួរចម្លើយនៅស២១ ត្រូវបានធ្វើឡើងដោយមនុស្សច្រើន ( តាមពិតទៅ តំបន់ ២១ បានបង្ហាញគ្រប់ឈ្មោះរបស់អ្នកទាំងអស់ដែលមានវត្តមាននាពេលសួរចម្លើយលីផែល ដូចដែលមានបង្ហាញនៅក្នុងឯកសារ ERN 00172698)។

**សំនួររបស់លោកសហចៅក្រមស៊ើបអង្កេតៈ** តាមរយៈឯកសារជាច្រើនដែលពាក់ព័ន្ធនឹងចម្លើយសារភាពរបស់លីផែល បង្ហាញថា រយៈពេលសួរចម្លើយគាត់ មានពេលរាប់ខែ។ ការឆ្លើយសារភាព ចាប់ផ្តើមដំបូងនៅខែមិថុនា ឆ្នាំ ១៩៧៦ (ERN 00172746-00172747) ហើយ ត្រូវបានបន្តរហូតដល់ខែកក្កដា ឆ្នាំ១៩៧៦ (ERN 00172743) ដែលឈ្មោះរបស់លោកត្រូវបានដាក់ថាជាអ្នកសួរចម្លើយទី១នៅថ្ងៃទី១៩ កញ្ញា ១៩៧៦ ( ERN 00172738) ហើយ ដែលការដកស្រង់មួយចុះហត្ថលេខាដោយលោកនៅថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ១៩៧៦ ( ERN 00172767)។ តើលោកច្បាស់ទេថាលោកមិនបានចូលរួមក្នុងការសួរចម្លើយនេះ?

**ឆ្លើយៈ** ខ្ញុំ ពិតប្រាកដណាស់។ ខ្ញុំ អាចតាមដានការវិវត្តនៃការសួរចម្លើយនេះបានគ្រប់ពេលដោយកោះហៅប៉ុន។ ខ្ញុំ មិនចាំចំនុចលម្អិតទាំងអស់ទេ ប៉ុន្តែ ខ្ញុំ នៅចាំថា សុនសេន ស្អប់លីផែលដែលគាត់ចាត់ទុកថាជាអ្នក Machiavél និយម។ ហើយ ខ្ញុំ បានឆ្លើយទៅគាត់វិញថាចំពោះខ្ញុំ ខ្ញុំ ចូលចិត្ត Stoïcisme។

**សំនួររបស់លោកសហចៅក្រមស៊ើបអង្កេតៈ** ហេតុអ្វីបានជាគេត្រូវបង្ហាញឈ្មោះអ្នកសួរចម្លើយច្រើនគ្នា ដើម្បីបង្ហាញទៅតំបន់២១?

**ឆ្លើយៈ** វា គ្រាន់តែជាការបកស្រាយផ្ទាល់ខ្លួនរបស់ខ្ញុំប៉ុណ្ណោះ។ ប៉ុន្តែ ខ្ញុំ សុំបញ្ជាក់ថា ចម្លើយសារភាពត្រូវផ្ញើរដោយស្វ័យប្រវត្តិទៅអង្គភាពរបស់ជនដែលត្រូវបានគេសួរចម្លើយ។ នេះ ជាមូលហេតុដែល *“ឈ្មោះរបស់តា (សោភឹម)”* ត្រូវបានដកចេញ។

☒ ឯកសារច្បាប់ដើមនៃការថតរូបភាពនិងសម្លេង ត្រូវបានបិទស្លាកបោះត្រានៅចំពោះមុខជនត្រូវចោទនេះ និង មេធាវីរបស់ជននេះ និង ត្រូវបានចុះហត្ថលេខាដោយ យើង ក្រឡាបញ្ជី សហព្រះរាជអាជ្ញា ជនត្រូវចោទ និង មេធាវីរបស់ជននេះ។

☒ ឯកសារច្បាប់ដើមមួយច្បាប់នៃការថតរូបភាពនិងសម្លេង ត្រូវបានប្រគល់ឲ្យជនត្រូវចោទនេះ។

នៅវេលាម៉ោងដប់ប្រាំពីរ និងសាមសិបប្រាំនាទីល្ងាច យើងបានឲ្យក្រឡាបញ្ជីអានខ្លាំងៗនូវកំណត់ហេតុសួរចម្លើយរបស់ជនត្រូវចោទនេះ ទៅតាមអ្វីដែលបានកត់ត្រា។

☒ អានឲ្យស្ដាប់ហើយ ជនត្រូវចោទ មិនមានជំទាស់អ្វីទេ ហើយ សុខចិត្តចុះហត្ថលេខា។

| ជនត្រូវចោទ | មេធាវីជនត្រូវចោទ | សហព្រះរាជអាជ្ញា | អ្នកបកប្រែ | ក្រឡាបញ្ជី | សហចៅក្រមស៊ើបអង្កេត |
|---|---|---|---|---|---|
| **Charged person**<br>**Personne mise en examen** | **Lawyer of Charged person**<br>**Avocat de la Personne mise en examen** | **C0-Prosecutors**<br>**Co-procureurs** | **Interpreter**<br>**Interprète** | **Greffiers** | **Co-Investigating Judges**<br>**Co-juges d'instruction** |